**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រុមប្រឹក្សា
កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
អង្គភាពគ្រប់គ្រងគម្រោង
លេខ:០០៣/០៩ រប.អគគ

# របាយការណ៍ស្តីពីសកម្មភាពការងារប្រចាំខែ មករា ឆ្នាំ ២០០៩របស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងទិសដៅសម្រាប់អនុវត្តបន្ត

ក្នុងខែ មករា ឆ្នាំ ២០០៩ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដោយមានអង្គភាពគ្រប់គ្រងគម្រោង ជាអង្គភាពប្រតិបត្តិ បានដំណើរការការងាររបស់ខ្លួនស្របតាមបេសកកម្មដែលបានកំណត់ក្នុងស្មារតី ទទួលខុសត្រូវខ្ពស់ ហើយសម្រេចបាននូវលទ្ធផលជាក់ស្តែងដូចខាងក្រោម ៖

## ១-ការងារកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

### ក. ការងាររដ្ឋបាល

-ទទួលលិខិតស្នើចាត់តាំងសមាជិកក្នុងក្រុមការងារបច្ចេកទេសចម្រុះ ស្តីពីភាពជាដៃគូ និងសុខុមដុមនីយកម្ម ពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា កាលពីថ្ងៃទី០៥ ខែមករា ឆ្នាំ២០០៩

-ទទួលលិខិតអញ្ជើញពីទីស្តីការគណៈរដ្ឋមន្ត្រី ដោយអញ្ជើញនាយកអង្គភាពគ្រប់គ្រងគម្រោងជាកិត្តិយស ដែលឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ទទួលជួបប្រធានធនាគារពិភពលោកថ្មីទទួលបន្ទុកប្រទេសកម្ពុជា ដែលនឹងប្រព្រឹត្តទៅ នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០០៩ នៅទីស្តីការគណៈរដ្ឋមន្ត្រី (អតីតរដ្ឋសភា)

-ទទួលបានផែនការយុទ្ធសាស្ត្រសម្រាប់សាលាដំបូង និងអយ្យការអមសាលាដំបូងក្រុងភ្នំពេញ ពីក្រុមការងារតុលាការគំរូសាលាដំបូងក្រុងភ្នំពេញ កាលពីថ្ងៃទី១៣ ខែមករា ឆ្នាំ២០០៩

-ទទួលលិខិតចាត់តាំងមន្ត្រីជាន់ខ្ពស់រដ្ឋលេខាធិការអាកាសចរស៊ីវិល ដើម្បីចូលរួមសិក្ខា-សាលាស្តីពីការ ស្ទង់មតិជាមូលដ្ឋាននៃការពង្រឹងអង្គភាពនីតិកម្មនៅតាមក្រសួង កាលពីថ្ងៃទី១៥ ខែមករា ឆ្នាំ២០០៩

-ទទួលលិខិតចាត់តាំងមន្ត្រីបីរូបពីក្រសួងព័ត៌មាន ដើម្បីចូលរួមសិក្ខាសាលាស្តីពីការស្ទង់មតិជាមូលដ្ឋាន នៃការពង្រឹងអង្គភាពនីតិកម្មនៅតាមក្រសួង កាលពីថ្ងៃទី១៤ ខែមករា ឆ្នាំ២០០៩

-ទទួលលិខិតអញ្ជើញពីក្រសួងមហាផ្ទៃ ដើម្បីចូលរួមប្រជុំក្រុមប្រឹក្សាភិបាលជាតិ គ្រប់គ្រងគម្រោងជំនួយផ្នែកព្រហ្មទណ្ឌ និងយុត្តិធម៌នៅកម្ពុជាដំណាក់កាលទី៣ ដែលកិច្ចប្រជុំនោះនឹងប្រព្រឹត្តទៅ នៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៩ នៅសណ្ឋាគារសាន់វេ

-ទទួលបានសៀវភៅ "ក្របខ័ណ្ឌយុទ្ធសាស្ត្រសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅកម្ពុជា ២០០៨-២០១២" ពីក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីថ្ងៃទី១៤ ខែមករា ឆ្នាំ២០០៩

-ទទួលលិខិតចាត់តាំងមន្ត្រីចំនួន ៣រូប នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីចូលរួម សិក្ខាសាលាស្តីពីការស្ទង់មតិជាមូលដ្ឋាននៃការពង្រឹងអង្គភាពនីតិកម្ម នៅតាមក្រសួង កាលពីថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៩

-ទទួលលិខិតអញ្ជើញពីអង្គការជំនួយផ្នែកច្បាប់នៅកម្ពុជា ដើម្បីចូលរួមសិក្ខាសាលាថ្នាក់ជាតិ មួយក្រោម អធិបតីភាពរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ស្តីពី "ការប្រឈម និងមេរៀនដែលទទួលបាន" ដែលនឹងប្រព្រឹត្តទៅ នៅថ្ងៃទី ២៨ ខែមករា ឆ្នាំ២០០៩ នៅសណ្ឋាគារសាន់វេ

-ទទួលរបាយការណ៍ពីក្រុមប្រឹក្សាភិបាលជាតិគ្រប់គ្រងគម្រោងជំនួយផ្នែកព្រហ្មទណ្ឌ និងយុត្តិធម៌នៅកម្ពុជា នៅដំណាក់កាលទី៣ ប្រចាំត្រីមាសទី៤ កាលពីថ្ងៃទី២១ ខែមករា ឆ្នាំ ២០០៩។

-ផ្ញើលិខិតស្នើសុំទៅតាមក្រសួងនានា ដើម្បីចាត់តាំងមន្ត្រីចូលរួមសិក្ខាសាលាស្តីពីការស្ទង់មតិជាមូលដ្ឋាន នៃការពង្រឹងអង្គភាពនីតិកម្ម នៅតាមក្រសួង ដែលនឹងប្រព្រឹត្តទៅ នៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០០៩

-ផ្ញើរបាយការណ៍ជូនអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ស្តីពីវឌ្ឍនភាព នៃការអនុវត្តផែនការសកម្មភាពអភិបាលកិច្ចទី២ ប្រចាំឆ្នាំ២០០៨ លើវិស័យកំណែទម្រង់ច្បាប់ និងតុលាការ កាលពីថ្ងៃទី២០ ខែមករា ឆ្នាំ២០០៩។

-ផ្ញើលិខិតទៅអគ្គលេខាធិការរង នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដោយចាត់បញ្ជូនឈ្មោះ មន្ត្រីរាជការ ចំនួន១រូប នៃអង្គភាពគ្រប់គ្រងគម្រោង ដើម្បីចូលរួមសិក្ខាសាលាស្តីពី Monitoring and Evaluation on ODA Project នៅប្រទេសម៉ាឡេស៊ី ដែលនឹងប្រព្រឹត្តទៅ នៅថ្ងៃទី០៣-០៥ ខែកុម្ភៈ ឆ្នាំ២០០៩។

## ខ. ការងារកំណែទម្រង់

-រៀបចំកិច្ចប្រជុំក្រុមប្រតិបត្តិគម្រោងសិទ្ធិទទួលបានយុត្តិធម៌ នៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០០៩ នៅ សាលប្រជុំក្រសួងយុត្តិធម៌ នៅសាលប្រជុំក្រសួងយុត្តិធម៌

-ចូលរួមអង្គប្រជុំលើកទី១ ដោយពិភាក្សាបន្តលើ (១)សេចក្តីព្រាងព្រះរាជក្រឹត្យ ស្តីពីការកែសម្រួល មាត្រា១ និងមាត្រា៦ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥៨ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០២ ស្តីពី ការបង្កើតក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និង (២)សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដែលនឹងប្រព្រឹត្តទៅ នៅថ្ងៃពុធ ទី២៨ ខែមករា ឆ្នាំ២០០៩ នៅទីស្តីការគណៈរដ្ឋមន្ត្រី។

-រៀបចំសិក្ខាសាលាស្តីពីការស្ទង់មតិជាមូលដ្ឋាននៃការពង្រឹងអង្គភាពនីតិកម្ម នៅតាមក្រសួង ដែលនឹងប្រព្រឹត្តទៅ នៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០០៩ នៅសណ្ឋាគារកាំបូឌីយ៉ាណា។

## គ. ផ្សេងៗ

-ចូលរួមប្រជុំអន្តរក្រសួង។

## ២-សន្និដ្ឋាន

ក្នុងខែ មករា ឆ្នាំ២០០៩ នេះ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដោយមានអង្គភាព គ្រប់គ្រងគម្រោងជាអង្គភាពប្រតិបត្តិ បានរៀបចំកិច្ចប្រជុំក្រុមប្រតិបត្តិ គម្រោងសិទ្ធិទទួលបានយុត្តិធម៌នៅកម្ពុជា ដើម្បីពិនិត្យ និងសម្រេចលើរបាយការណ៍ប្រចាំឆ្នាំ២០០៨ ស្តីពីសមិទ្ធផលដែលទទួលបាន និងផែនការសកម្មភាព សម្រាប់រយៈពេលបន្តដល់ចុងឆ្នាំ២០០៩ និងលើការងារមួយចំនួនទៀត។ បន្ថែមពីលើនេះទៀត អង្គភាពគ្រប់គ្រងគម្រោងបានសហការជាមួយនឹងអង្គការអាល្លឺម៉ង់ GTZ ដើម្បីរៀបចំសិក្ខាសាលាមួយស្តីពីការស្ទង់មតិជាមូលដ្ឋាន នៃការពង្រឹងអង្គភាពនីតិកម្ម នៅតាមក្រសួងដោយទទួលលទ្ធផលពីគ្រប់បណ្តាក្រសួងពាក់ព័ន្ធ។

## ៣-ទិសដៅអនុវត្តក្នុងខែកុម្ភៈ ឆ្នាំ២០០៩

-បន្តអនុវត្តគម្រោងតុលាការគំរូ

-បន្តអនុវត្តគម្រោងប្រព័ន្ធសូចនាករ និងការតាមដានកំណែទម្រង់ច្បាប់ និងតុលាការ

-បន្តអនុវត្តគម្រោងប្រព័ន្ធទិន្នន័យស្តីពីការលើកកំពស់សិទ្ធិនៅតាមមូលដ្ឋាន

-បន្តអនុវត្តគម្រោងកិច្ចសហប្រតិបត្តិការជាមួយ GTZ

-រៀបចំក្រុមការងារបច្ចេកទេសចម្រុះសម្រាប់កំណែទម្រង់ច្បាប់ និងតុលាការ

-រៀបចំប្រជុំក្រុមប្រឹក្សាប្រតិបត្តិគម្រោងលទ្ធភាពទទួលបានយុត្តិធម៌

-រៀបចំប្រជុំគណៈកម្មាធិការអនុម័តមូលនិធិបត់បែនរបស់គម្រោង CCJAPIII

-ត្រៀមប្រជុំអន្តរក្រសួង ដើម្បីការពារសេចក្តីព្រាងព្រះរាជក្រឹត្យ និងអនុក្រឹត្យ សម្រាប់រចនាសម្ព័ន្ធថ្មី របស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌។

រាជធានីភ្នំពេញ, ថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០៩

**អ្នកធ្វើរបាយការណ៍**

**ហ៊ីង សុកុល**

បានឃើញ និងឯកភាព

នាយកអង្គភាពគ្រប់គ្រងគម្រោង

**ស៊ុយ ម៉ុងលាង**